ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ :...៥៤០...អនក្រ.បក

# អនុក្រឹត្យ

## ស្តីពីការបង្កើតកំពង់ផែស្វយ័តក្រុងព្រះសីហនុ ក.ស.ស

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី ២៤ ខែកញ្ញា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងនាយករដ្ឋមន្ត្រីទី១និង នាយករដ្ឋមន្ត្រីទី២ នៃរាជរដ្ឋាភិបាល
- បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រម លេខ ០២ នស ៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យ លេខ នស_រកត_១០៩៤_៨៣_ចុះថ្ងៃទី២៤_១០_៩៤ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាល
- បានឃើញព្រះរាជក្រឹត្យ លេខ ជស.រកត.០៨៩៧_១៩៧ ចុះថ្ងៃទី០៧ ខែសីហា ឆ្នាំ១៩៩៧ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាល
- បានឃើញព្រះរាជក្រម នស.រកម_ ០១_៩៦_០៣ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ស្តីពីការបង្កើតក្រសួងសាធារណការនិងដឹកជញ្ជូន
- បានឃើញព្រះរាជក្រមលេខ នស រកម ០១៩៦_១៨ ចុះថ្ងៃទី២៤ ខែ មករា ឆ្នាំ១៩៩៦ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ០៦៩៦/០៣ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ១៩៩៦ ស្តីពីលក្ខន្តិកៈទូទៅនៃសហគ្រាសសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ៩១ អនក្រ.បក ចុះថ្ងៃទី០៦ ខែសីហា ឆ្នាំ១៩៩៧ ស្តីពីការអនុវត្តព្រះរាជក្រមស្តីពីលក្ខន្តិកៈទូទៅនៃសហគ្រាសសាធារណៈ

- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន និងរបស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

## សម្រេច

## ជំពូក១

## បទបញ្ញត្តិទូទៅ

**មាត្រា១** ត្រូវបានបង្កើតសហគ្រាសសាធារណៈដែលមានលក្ខណៈជាក្រុមហ៊ុនរដ្ឋឈ្មោះ " កំពង់ផែស្វយ័តក្រុងព្រះសីហនុ " សរសេរកាត់ (**ក.ស.ស** ) Port Autonome de Sihanoukville (PAS) ដែលស្ថិតក្រោម អាណាព្យាបាលរបស់ក្រសួង សាធារណការ និងដឹកជញ្ជូន និងក្រោមអាណាព្យាបាលហិរញ្ញវត្ថុ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

- **ក.ស.ស** មានទីស្នាក់ការនៅ ក្រុងព្រះសីហនុ
- **ក.ស.ស** គឺជានីតិបុគ្គលមានស្វ័យភាពផ្នែកបច្ចេកទេសផ្នែករដ្ឋបាលនិងផ្នែកហិរញ្ញវត្ថុ។
- **ក.ស.ស** ត្រូវស្ថិតក្រោមឥទ្ធិពលបទបញ្ញត្តិនៃអនុក្រឹត្យនេះ ហើយនឹងគោរពតាមបទបញ្ញត្តិនៃព្រះរាជក្រម លេខ ០៦៩៦.០៣ ចុះថ្ងៃទី ១៧ ខែមិថុនា ឆ្នាំ ១៩៩៦ ស្តីពីលក្ខន្តិកៈទូទៅនៃសហគ្រាស សាធារណៈ ព្រមទាំងបទបញ្ញត្តិនៃច្បាប់ពាណិជ្ជកម្ម ។

**មាត្រា២** **ក.ស.ស** មានភារកិច្ចធ្វើអាជីវកម្ម _សេវាកម្មមូលដ្ឋានលើការងារ :

- កណ្តូធារកិច្ច នាំនាវាចេញ_ចូល និងផ្តល់ភស្តុភារដល់នាវា
- លើកដាក់ផ្ទេរ _ ផ្ទុក និងដឹកជញ្ជូនទំនិញ
- ការងារថែរក្សា ស្តុកទំនិញ ឃ្លាំង ទីលាន
- ការងារអភិវឌ្ឍ និងស្តារហេដ្ឋារចនាសម្ព័ន្ធ **ក.ស.ស** ដែលមាន ដែលត្រូវពង្រីក

**មាត្រា៣** **ក.ស.ស** មានភារកិច្ច :

- ទទួលខុសត្រូវ និងចាត់ចែងលើការងារការពារសុវត្ថិភាព សន្តិសុខ សណ្តាប់ធ្នាប់ក្នុងតំបន់គ្រប់គ្រង ។
- ប្រកាន់គោលការណ៍ និងរបៀបកិច្ចការ ដូចគ្នានឹងអាជីវករ ។
- គ្រប់គ្រងដឹកនាំ និងចាត់ចែងសកម្មភាពឱ្យមានប្រសិទ្ធភាព និងមានការរីកចំរើន ។
- ក្នុងឋានៈជាស្ថាប័នសាធារណៈ **ក.ស.ស** ទទួលពីរដ្ឋ នូវអំណាច និងកាតព្វកិច្ចទាំងឡាយ ដើម្បីបំពេញ បេសកកម្មស្របតាមកម្មវត្ថុរបស់ខ្លួន ។

មាត្រា៤ លើកលែងបទបញ្ញត្តិផ្ទុយពីនេះ ក.ស.ស ត្រូវបង់ពន្ធអាករស្របតាមច្បាប់និងបទបញ្ញា ជាធរមាន

មាត្រា៥ ដើមទុនដំបូងនៃ ក.ស.ស ត្រូវកំណត់ដោយបញ្ជីតុល្យការដំបូង ដែលបានទទួលការ ឯកភាពពីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងក្រសួងសាធារណការនិងដឹកជញ្ជូន ។

_ពេលដែលអនុក្រឹត្យនេះចូលជាធរមាន ក.ស.ស ត្រូវចាត់ទុកជាម្ចាស់កម្មសិទ្ធិពេញច្បាប់ ជំនួសរដ្ឋលើទ្រព្យសម្បត្តិទាំងអស់ ដែលបានកត់ត្រាក្នុងបញ្ជីសារពើភ័ណ្ឌ ។

មាត្រា៦ បុគ្គលិករបស់ ក.ស.ស ត្រូវស្ថិតនៅក្រោមលក្ខន្តិកៈដោយឡែក ដែលសំរេចដោយ ក្រុមប្រឹក្សាភិបាល ដោយផ្អែកលើព្រះរាជក្រម ស្តីពីលក្ខន្តិកៈទូទៅនៃសហគ្រាសសាធារណៈ ។ ចាប់ពីពេលដែលលក្ខន្តិកៈដោយឡែកនេះ ចូលជាធរមានបុគ្គលិករបស់ ក.ស.ស មិនស្ថិតក្នុងក្របខ័ណ្ឌរបស់រដ្ឋតទៅទៀតទេ ។

## ជំពូក២

## ការដឹកនាំ និងការគ្រប់គ្រង

មាត្រា៧ ក.ស.ស ត្រូវដឹកនាំដោយក្រុមប្រឹក្សាភិបាល ដែលមានសិទ្ធិយ៉ាងធំទូលាយ ដើម្បីបំពេញការងារក្នុងក្របខ័ណ្ឌ នៃបទបញ្ញត្តិនៃអនុក្រឹត្យនេះ និងបទបញ្ជាផ្ទៃក្នុងរបស់ខ្លួន ។

-ក្រុមប្រឹក្សាភិបាលមានសមាសភាពដូចខាងក្រោម :

| | |
|---|---|
| _ តំណាងក្រសួងសាធារណការ និងដឹកជញ្ជូន | ១ រូប ជាប្រធាន |
| _ តំណាងទីស្តីការគណៈរដ្ឋមន្ត្រី | ១ រូប ជាសមាជិក |
| _ តំណាងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | ១ រូប ជាសមាជិក |
| _ តំណាងអាជ្ញាធរក្រុងព្រះសីហនុ | ១ រូប ជាសមាជិក |
| _ តំណាងក្រសួងពាណិជ្ជកម្ម | ១ រូប ជាសមាជិក |
| _ តំណាងនិយោជិករបស់ ក.ស.ស | ១ រូប ជាសមាជិកស្វ័យប្រវត្តិ |
| _ អគ្គនាយក ក.ស.ស | ១ រូប ជាសមាជិក |

មាត្រា៨ សមាជិកក្រុមប្រឹក្សាភិបាល ត្រូវជ្រើសរើសក្នុងចំណោមមន្ត្រីសកម្ម ធ្លាប់បានបំរើការងារ យ៉ាងតិច០៥ (ប្រាំ) ឆ្នាំ ឬជាឥស្សរជន ដែលមានអាយុមិនលើសពី ៦៥ ឆ្នាំ និងមានបទពិសោធន៍ការងារគ្រប់គ្រាន់ ព្រមទាំងមានជំនាញខ្ពស់ក្នុងវិស័យសេដ្ឋកិច្ច វិទ្យាសាស្ត្រ ឬនីតិសាស្ត្រដែល មានសញ្ជាតិខ្មែរ និងពុំដែលទទួលទណ្ឌកម្ម ព្រហ្មទណ្ឌកិរិតធ្ងន់ ពីតុលាការឡើយ ។

- សមាជិកក្រុមប្រឹក្សាភិបាល ត្រូវតែងតាំងដោយ អនុក្រឹត្យសំរាប់អាណត្តិ ៣ឆ្នាំ ។ អាណត្តិនេះ អាចបញ្ចប់បានគ្រប់ពេលវេលា និងអាចបន្តទៀតបាន ដោយអនុក្រឹត្យតាមសំណើ របស់ក្រសួង ឬ អាជ្ញាធរដែលខ្លួនតំណាងឱ្យ ។

- តំណាងនិយោជិត ត្រូវជ្រើសរើសដោយបោះឆ្នោត ក្នុងចំណោមនិយោជិត **ក.ស.ស** ។

មាត្រា៩ ក្រុមប្រឹក្សាភិបាលមានសិទ្ធពេញលេញ ដើម្បីសំរេចក្នុងនាមនៃ **ក.ស.ស** ក្នុងការរៀបចំលិខិតស្នាមរាល់ឯកសារផ្សេងៗ ទាក់ទងនឹងកម្មវត្ថុរបស់សហគ្រាស ស្របតាមច្បាប់ជាធរមាន មានជាអាទិ៍ :

១- ផ្តល់ការយល់ព្រមលើគំរោងសហគ្រាស ដូចមានចែងក្នុងមាត្រា ១៨ នៃអនុក្រឹត្យនេះ ។

២- វាយតំលៃរៀងរាល់ពេល នូវលទ្ធផលដែលបានគ្រោងទុក ព្រមទាំងចាត់វិធានការ ដើម្បីកែសំរួលឱ្យបានសមស្របតាមសភាពការណ៍ ។

៣- ផ្តល់ការយល់ព្រមលើតុល្យការ និងគណនីប្រចាំឆ្នាំ និងរបាយការណ៍សកម្មភាពរបស់ **ក.ស.ស**។

៤- សំរេច តាមសំណើរបស់អគ្គនាយក នូវរចនាសម្ព័ន្ធ និងបទបញ្ជាផ្ទៃក្នុងរបស់សហគ្រាស ព្រមទាំងលក្ខន្តិកៈនិងកាំប្រាក់បៀវត្ស ប្រាក់រង្វាន់ ប្រាក់ឧបត្ថម្ភផ្សេងៗ សំរាប់បុគ្គលិកដោយ អនុលោមតាមច្បាប់ និងបទបញ្ញត្តិទាំងឡាយជាធរមាន ។

៥- ផ្តល់ការយល់ព្រមលើកិច្ចសន្យា និងអនុសញ្ញាដែល **ក.ស.ស** ជាភាគីស្របតាមលំក្ខខណ្ឌនិងបែបបទដូចមានគ្រោង ក្នុងបទបញ្ជាជាធរមាន ស្តីពីកិច្ចសន្យានិងអនុសញ្ញា ដែលចុះដោយសហគ្រាសសាធារណៈ ។

៦- សំរេចបង្កើត បើក ឬបិទ ការិយាល័យ និងទីភ្នាក់ងារគ្រប់ទីកន្លែងរបស់ **ក.ស.ស** តាមការវិនិច្ឆ័យរបស់ខ្លួន ។

៧- កំណត់លើតំលៃឈ្នួលពាក់ព័ន្ធនិងការធ្វើអាជីវកម្ម សេវាកម្ម លើកំពង់ផែ ។

មាត្រា១០: ក្រុមប្រឹក្សាភិបាល បើកអង្គប្រជុំគ្រប់ពេល អាស្រ័យដោយអត្ថប្រយោជន៏នៃសហគ្រាសតាមការអញ្ជើញរបស់ប្រធាន ឬតាមសំណើនៃសមាជិកដែលមានបួននាក់យ៉ាងតិច ក្នុងចំណោមសមាជិកទាំងអស់ ។

ទោះជាយ៉ាងណាក៏ដោយក្រុមប្រឹក្សាភិបាលត្រូវធ្វើការប្រជុំយ៉ាងតិច ១ដងក្នុងរយៈពេល ៣ខែ។

ករណីប្រធានមានធុរៈ ត្រូវជ្រើសរើសសមាជិកណាម្នាក់ ដែលមានវ័យចំណាស់ជាងគេ ដើម្បីដឹកនាំការប្រជុំ ។

ក្រុមប្រឹក្សាភិបាលត្រូវពិភាក្សាលើបញ្ហាទាំងឡាយ ដែលស្ថិតក្នុងក្របខំណ្ឌរបស់ខ្លួន ។ របៀបវារៈនៃការប្រជុំ ព្រមទាំងឯកសារទាក់ទិនទាំងឡាយ ត្រូវផ្ញើជូនសមាជិកក្រុមប្រឹក្សាភិបាលគ្រប់រូប និងមន្ត្រីត្រួតពិនិត្យរដ្ឋ ឱ្យបានយ៉ាងតិច ១០ថ្ងៃ មុនពេលបើកអង្គប្រជុំ ។

- កិច្ចប្រជុំរបស់ក្រុមប្រឹក្សាភិបាល អាចប្រព្រឹត្តទៅបានលុះណាតែមានវត្តមានសមាជិក យ៉ាងតិចពាក់កណ្តាល ។ បើសិនជាមិនគ្រប់កូរ៉ុមទេ ការប្រជុំត្រូវលើកទៅ ១៥ ថ្ងៃក្រោយទៀត ដើម្បី

ពិភាក្សាឡើងវិញ ហើយបញ្ជាតាមរបៀបវារៈដដែល ។ កិច្ចប្រជុំលើកក្រោយនេះ ពុំចាំបាច់ទាមទារកូរ៉ុមទេ ។

- សេចក្ដីសំរេចទាំងឡាយរបស់ក្រុមប្រឹក្សាភិបាលអាចយកជាការបាន លុះត្រាតែមានការ អនុម័តដោយសំឡេងភាគច្រើន នៃសមាជិកអង្គប្រជុំ ។ បើសិនជាការចែកសំឡេង មានចំនួនស្មើគ្នា សំឡេងរបស់ប្រធាន ត្រូវចាត់ទុកជាឧត្ដមភាព ។

មាត្រា១១ សេចក្ដីសំរេចនៃក្រុមប្រឹក្សាភិបាល ត្រូវកត់ត្រាក្នុងកំណត់ហេតុមួយ ដែលត្រូវបញ្ជូនទៅ អាជ្ញាធរអាណាព្យាបាល ទៅសមាជិកក្រុមប្រឹក្សាភិបាលម្នាក់ៗ និងទៅមន្ត្រីត្រួតពិនិត្យរដ្ឋ ព្រមទាំងស្ថាប័ន ដទៃទៀត ដែលមានចែងក្នុងមាត្រា២៤ នៃអនុក្រឹត្យនេះ ក្នុងរវាង១៥ ថ្ងៃយ៉ាងយូរចាប់រាប់ពីថ្ងៃប្រជុំ ។ កំណត់ហេតុដើម ត្រូវមានចុះហត្ថលេខាដោយប្រធាននៃអង្គប្រជុំ និងសមាជិកក្រុមប្រឹក្សាភិបាលណាម្នាក់ ដែលមានវត្តមានក្នុងកិច្ចប្រជុំពេលមុននោះ ។

មាត្រា១២ អគ្គនាយកមានភារកិច្ច ជាអ្នកគ្រប់គ្រងជាប្រក្រតីនៃ **ក.ស.ស** និងត្រូវបានតែងតាំងសំរាប់ អាណត្តិ ៣ ឆ្នាំ ដោយអនុក្រឹត្យ តាមសំណើរបស់ក្រសួងអាណាព្យាបាល ។

មាត្រា១៣ ក្រុមប្រឹក្សាភិបាល ត្រូវប្រគល់ជូនអគ្គនាយកនូវអំណាចចាំបាច់ សំរាប់ដំណើរការប្រចាំថ្ងៃ ដើម្បីមានលទ្ធភាពគ្រប់គ្រាន់ សំរាប់ដឹកនាំសហគ្រាសស្របតាមច្បាប់ និងការណែនាំរបស់ក្រុមប្រឹក្សាភិបាល ។

ក្នុងក្របខ័ណ្ឌនេះអគ្គនាយកត្រូវ ៖

១_ រៀបចំឯកសារទាំងឡាយ ដើម្បីដាក់ជូនក្រុមប្រឹក្សាភិបាល ចាត់ចែងអនុវត្តរាល់សេចក្ដីសំរេច របស់ក្រុមប្រឹក្សាភិបាល ។ តាមដំណាក់កាលនីមួយៗ អគ្គនាយកត្រូវរាយការណ៍ជូន ក្រុមប្រឹក្សា ភិបាល អំពីសកម្មភាពរបស់ **ក.ស.ស** ។

២_ ទទួលដឹកនាំ **ក.ស.ស** លើផ្នែករដ្ឋបាល បច្ចេកទេស អាជីវកម្ម និងហិរញ្ញវត្ថុ ។

៣_ តំណាងឱ្យ **ក.ស.ស** ចំពោះមុខតតិយជនទាំងឡាយ ក្នុងការបំពេញលិខិតស្នាមស៊ីវិលរដ្ឋបាល ឬលិខិតតុលាការក្នុងក្របខ័ណ្ឌច្បាប់ និងការសំរេចរបស់ក្រុមប្រឹក្សាភិបាល ។

៤_ មានសិទ្ធិជ្រើសរើស តែងតាំង ដកហូតដំណែង ឬបញ្ឈប់ការងារ និងមានសិទ្ធិបញ្ជាត្រួតត្រាបណ្ដាភ្នាក់ងារ ឬមន្ត្រីគ្រប់រូបដែលជានិយោជិតរបស់ **ក.ស.ស** ដោយអនុវត្តតាម ( លក្ខន្តិកៈបុគ្គលិក ) ឬច្បាប់ជាធរមាន និងតាមការសំរេចរបស់ក្រុមប្រឹក្សាភិបាល ។

៥_ មានសិទ្ធិផ្ទេរអំណាចមួយភាគ ឬទាំងអស់ រួមទាំងការផ្ទេរសិទ្ធិចុះហត្ថលេខាទៅមន្ត្រី ដែលនៅក្រោមឱវាទស្របតាមលក្ខខ័ណ្ឌដែលបានកំណត់ដោយក្រុមប្រឹក្សាភិបាល ។

តំណាងឱ្យ **ក.ស.ស** ចំពោះមុខតុលាការ និងសាលាជំរះក្ដីគ្រប់ជាន់ថ្នាក់ ក្នុងករណីចោទប្រកាន់តវ៉ាការពារក្ដីឱ្យ **ក.ស.ស** និងការប្ដឹងជំទាស់ផ្សេងៗ ។

**មាត្រា១៤** លាភការរបស់ក្រុមប្រឹក្សាភិបាល និងប្រាក់បំណាច់ របស់អគ្គនាយកត្រូវកំណត់ដោយក្រសួងអាណាព្យាបាល និងក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ តាមសំណើរបស់ក្រុមប្រឹក្សាភិបាល ។

**មាត្រា១៥** ការចុះ និងការអនុវត្តកិច្ចសន្យាដោយ ក.ស.ស ត្រូវគោរពតាមបែបបទ និងនីតិវិធីដែលកំណត់ដោយច្បាប់ជាធរមាន ។

## ជំពូក៣

## ការគ្រប់គ្រងហិរញ្ញវត្ថុ

**មាត្រា១៦** ក.ស.ស កាន់កាប់គណនេយ្យរបស់ខ្លួន ឱ្យបានសមស្របតាមបទបញ្ជាគណនេយ្យកម្ពុជា និងតាម វិធាននៃគណនេយ្យ ដែលគេទទួលស្គាល់ជាទូទៅ ។

ការិយបរិច្ឆេទគណនេយ្យ ចាប់ផ្តើមពីថ្ងៃ០១ ខែមករា ហើយបញ្ចប់នៅថ្ងៃ៣១ ខែធ្នូ នៃឆ្នាំដដែល ។

តុល្យការ និងគណនីគ្រប់គ្រងត្រូវកំណត់ដោយក្រុមប្រឹក្សាភិបាល មុនថ្ងៃ៣០ ខែមិនា នៃឆ្នាំបន្ទាប់ឆ្នាំបិទការិយបរិច្ឆេទ ឈរលើរបាយការណ៍នៃគណនេយ្យករជំនាញម្នាក់ ដែលមានមុខងារជាស្នងការគណនី ។

តុល្យការនិងគណនីគ្រប់គ្រង ព្រមទាំងរបាយការណ៍របស់ស្នងការគណនី ត្រូវដាក់សុំការយល់ព្រម ពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្នុងអំឡុងពេលមិនលើសពី ១៥ ថ្ងៃ រាប់ពីថ្ងៃ ដែលក្រុមប្រឹក្សាភិបាល បានពិនិត្យឯកសារទាំងឡាយ ។ ឯកសារទាំងនេះ ត្រូវបញ្ជូនទៅក្រសួងអាណាព្យាបាលផងដែរ ដើម្បីសុំមតិទៅតាមលក្ខខណ្ឌដែលមានចែងក្នុងមាត្រា ១៦ នៃច្បាប់ ស្តីពីលក្ខន្តិកៈនៃសហគ្រាសសាធារណៈ ។

**មាត្រា១៧** _ស្នងការគណនី ត្រូវបានតែងតាំងដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុសំរាប់អាណត្តិបីការិយបរិច្ឆេទ ។ អាណត្តិនេះអាចបន្តទៀតបានតាមសំណើ របស់ក្រុមប្រឹក្សាភិបាល ។

_ប្រាក់បំណាច់សំរាប់ស្នងការគណនី ត្រូវកំណត់ដោយក្រុមប្រឹក្សាភិបាល និងត្រូវចំណាយក្នុងជំពូកបន្ទុកអាជីវកម្មរបស់ ក.ស.ស ។

_ ស្នងការគណនី ត្រូវធ្វើរបាយការណ៍ដើម្បីបញ្ជាក់គណនីប្រចាំឆ្នាំ នៃការិយបរិច្ឆេទមានភាពស្មោះត្រង់ និងត្រឹមត្រូវល្អ ហើយឆ្លុះបញ្ចាំងអំពីភាពពិតប្រាកដនៃស្ថានភាពហិរញ្ញវត្ថុរបស់ ក.ស.ស ។

- បេសកកម្មរបស់ស្នងការគណនី អនុលោមតាមបទបញ្ញត្តិ នៃអនុក្រឹត្យលេខ ៤២ អ.ន-ក្រ.ប.ក ចុះថ្ងៃទី០៦ ខែសីហា ឆ្នាំ១៩៩៧ ស្តីពីស្នងការគណនីនៃសហគ្រាសសាធារណៈ ។

- ស្នងការគណនីអាចចូលរួមប្រជុំជាមួយក្រុមប្រឹក្សាភិបាលបាន តាមការអញ្ជើញរបស់ ប្រធានក្រុមប្រឹក្សាភិបាល ។

**មាត្រា១៨** រៀងរាល់ឆ្នាំ មុនថ្ងៃ ៣០ ខែកញ្ញា ក្រុមប្រឹក្សាភិបាល ត្រូវផ្តល់ការយល់ព្រមលើគំរោងសហគ្រាសប្រចាំឆ្នាំ តាមសំណើរបស់អគ្គនាយក ហើយបញ្ជូនគំរោងនេះដើម្បីសុំការអនុម័ត ពីរដ្ឋមន្ត្រីក្រសួងអាណាព្យាបាល និងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ។

គំរោងប្រចាំឆ្នាំត្រូវបញ្ជាក់នូវ ៖

១_ កម្មវិធីវិនិយោគ ព្រមទាំងហិរញ្ញប្បទានបំរុង សំរាប់សំរេចកម្មវិធីវិនិយោគនេះ ។

២_ ថវិកាសំរាប់ដំណើរការនៃសហគ្រាស ។

៣_ តម្លៃឈ្នួលលើកដាក់ប្រគល់ ដឹកជញ្ជូន និងតំលៃឈ្នួលសេវានាវាចរណ៍_ពន្ធផែ_ស្តុកឃ្លាំង ។

៤_ លក្ខណវិនិច្ឆ័យ សំរាប់វាស់វែងលទ្ធផលសេដ្ឋកិច្ច និង ហិរញ្ញវត្ថុរបស់ **ក.ស.ស** ។

**មាត្រា១៩** _ ធនធាននៃ **ក.ស.ស** ជាអាទិមាន ៖

- ប្រាក់ដើមទុនដែលរដ្ឋផ្តល់ឱ្យ ( តុល្យការដំបូង នៅពេលបង្កើត )
- ប្រាក់ចំណូលផ្សេងៗ គ្រប់ប្រភេទ បានមកពីសកម្មភាពរបស់សហគ្រាស ។
- ប្រាក់បានមកពីការលក់ ឬការជួលចលនវត្ថុ និងអចលនវត្ថុរបស់ **ក.ស.ស** ។
- ប្រាក់ខ្ចីបុល និងប្រាក់អំណោយផ្សេងៗ ។

**មាត្រា២០** ចំណាយនៃ **ក.ស.ស** រួមមាន ៖

- ចំណាយប្រក្រតីសំរាប់ដំណើរការ
- ចំណាយវិនិយោគ
- សងបំណុល
- ចំណាយផ្សេងៗ

**មាត្រា២១** **ក.ស.ស** អាចមានគណនីចរន្ត ក្នុងធនាគារពាណិជ្ជកម្មផ្សេងៗ ហើយប្រើប្រាស់គណនីនេះសំរាប់តំរូវការរបស់ខ្លួន ។

**មាត្រា២២** ជារៀងរាល់ឆ្នាំ ក្រោយពីមានការសំរេច ពីរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ប្រាក់ចំណេញដែល **ក.ស.ស** ទទួលបាន ក្រោយពីការទូទាត់ស្របតាមវិធានការគណនេយ្យ ដែលគេទទួលស្គាល់ ជាទូទៅត្រូវបញ្ចូលទៅក្នុងគណនីមូលនិធិបំរុងហិរញ្ញវត្ថុរបស់ **ក.ស.ស** ។

**មាត្រា២៣** ការខ្ចីបុលរយៈពេលមធ្យម ឬវែង សំរាប់ប្រើប្រាស់ក្នុងការវិនិយោគ ត្រូវមានការយល់ព្រមពីរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុជាមុន ។

## ជំពូក៤

## ការទំនាក់ទំនងជាមួយរដ្ឋ

**មាត្រា២៤** : រយៈពេល ១៥ ថ្ងៃ យ៉ាងយូរបំផុត ក្រោយពីការអនុម័តរបស់ក្រុមប្រឹក្សាភិបាល ក.ស.ស ត្រូវផ្ញើជូន រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអាណាព្យាបាល និងរដ្ឋមន្ត្រីក្រសួង សេដ្ឋកិច្ច និងហិរញ្ញវត្ថុ នូវឯកសារដូចខាងក្រោមនេះ ៖

- កំណត់ហេតុប្រជុំនៃក្រុមប្រឹក្សាភិបាល
- គំរោងសហគ្រាស( ដូចមានចែងក្នុងមាត្រា ១៨)
- របាយការណ៍ស្តីពីសកម្មភាព_តុល្យការ និងគណនីគ្រប់គ្រងទាំងឡាយរបស់ ក.ស.ស
- របាយការណ៍របស់ស្នងការគណនី ។

**មាត្រា២៥** ត្រូវបានដាក់ឱ្យនៅអម ក.ស.ស នូវមន្ត្រីត្រួតពិនិត្យរដ្ឋម្នាក់ ដែលត្រូវតែងតាំងដោយ អនុក្រឹត្យ តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។ មន្ត្រីត្រួតពិនិត្យរដ្ឋ មានសិទ្ធិចូលរួមគ្រប់កិច្ចប្រជុំរបស់ក្រុមប្រឹក្សាភិបាល ហើយអាចផ្តល់យោបល់លើគ្រប់ចំណុចនៃរបៀបវារៈតែពុំមានសំឡេងអនុម័តឡើយ ។ មន្ត្រីត្រួតពិនិត្យរដ្ឋត្រូវបំពេញបេសកកម្ម ដោយអនុលោមតាម បទបញ្ញត្តិនៃមាត្រាទី ២០ ទៅ ២៥ នៃព្រះរាជក្រមលេខ ជស_រកម_០៦៩៦/០៣ ចុះថ្ងៃទី១ ខែមិថុនា ឆ្នាំ១៩៩៦ ស្តីពីលក្ខន្តិកៈទូទៅនៃ សហគ្រាសសាធារណៈ ។

**មាត្រា២៦** ក.ស.ស មានសិទ្ធិផ្អាកការងារ ចំពោះអតិថិជន ឬឯកជនណាមួយ ដែលពុំព្រមបង់ប្រាក់ថ្លៃឈ្នួលផ្សេងៗ តាមកិច្ចសន្យា និងកិច្ចព្រមព្រៀង ។

## ជំពូក៥

## អវសានបញ្ញត្តិ

**មាត្រា២៧** បទបញ្ញត្តិទាំងឡាយ ដែលផ្ទុយនឹងអនុក្រឹត្យនេះត្រូវចាត់ទុកជានិរាករណ៍ ។ សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសាធារណការនិងដឹកជញ្ជូន រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង

ហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម អភិបាលក្រុងព្រះសីហនុ អគ្គនាយកកំពង់ផែក្រុងព្រះសីហនុ ត្រូវអនុវត្តនូវអនុក្រឹត្យនេះ ។

**មាត្រា២៨** អនុក្រឹត្យនេះ ចូលជាបទបញ្ញត្តិ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី១៧ ខែកក្កដា ឆ្នាំ ១៩៩៨

| នាយករដ្ឋមន្ត្រីទី១ | នាយករដ្ឋមន្ត្រីទី២ |
| --- | --- |
| អ៊ុង ហួត | ហ៊ុន សែន |

បានជំរាបជូន
ឯកឧត្តមនាយករដ្ឋមន្ត្រីទី១
សម្តេចនាយករដ្ឋមន្ត្រីទី២

| ជ. រដ្ឋមន្ត្រីក្រសួងសាធារណការនិងដឹកជញ្ជូន<br>រដ្ឋលេខាធិការ | ទេសរដ្ឋមន្ត្រីនិងជារដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ |
| --- | --- |
| ត្រាំ អ៊ីវតឹក | គាត ឈន់ |

**កន្លែងទទួល**

- ខុទ្ទកាល័យព្រះមហាក្សត្រ
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការដ្ឋានព្រះបរមរាជវាំង
- ខុទ្ទកាល័យឯកឧត្តមនាយករដ្ឋមន្ត្រីទី១
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រីទី២
- ដូចមាត្រា ២៧
- ឯកសារ_កាលប្បវត្តិ